# អំណាចនៃបព្វជិតភាព

*ប្រធាន បយដ៍ ឃេ ផាកកឺ*
*ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ខ្ញុំនិយាយទៅកាន់ក្រុមគ្រួសារ ជាពិសេសចំពោះឪពុក។ ជាច្រើនឆ្នាំកន្លងទៅ យើងបានចាប់ផ្តើមសហសម្ព័ន្ធនៅក្រោមការដឹកនាំរបស់ប្រធាន ហារូល ប៊ី លី។ នៅគ្រានោះ ប្រធានថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា៖ «សព្វថ្ងៃនេះ យើងត្រូវបានតាំងបន្ទាយប្រឆាំងនឹងប្រភេទនៃអំពើបាប អបាយមុខ និងសេចក្តីអាក្រក់ដ៏ធំបំផុត ដែលបានប្រមូលផ្តុំនៅចំពោះមុខយើង...។ ផែនការចម្បាំងដែលយើងច្បាំងដើម្បីសង្គ្រោះព្រលឹងរបស់មនុស្ស គឺពុំមែនជារបស់យើងផ្ទាល់ទេ។ ផែនការចម្បាំង [ចេញមកពី] ការបំផុសគំនិត និងវិវរណៈរបស់ព្រះអម្ចាស់»។ 1

នៅអំឡុងឆ្នាំទាំងនោះ រចនាសម្ព័ន្ធនៃការប្រតិបត្តិការរបស់សាសនាចក្រទាំងមូល ត្រូវបានផ្លាស់ប្តូរ។ កម្មវិធីសិក្សាទាំងមូលត្រូវបានរៀបចំរចនាសម្ព័ន្ធសារជាថ្មី។ គោលដៅ និងទំនាក់ទំនងរវាងអង្គការមួយទៅអង្គការមួយទៀត ត្រូវបានកំណត់ឡើងវិញ។ ពាក្យគន្លឹះអំឡុងពេលឆ្នាំនៃការធ្វើសហសម្ព័ន្ធ និងការរៀបចំរចនាសម្ព័ន្ធសារជាថ្មីទាំងនោះ  គឺ *បព្វជិតភាព*។

ប្រធាន ម៉នសុន ក៏បានមានប្រសាសន៍អំពីគេឌាន ដែលជាវិរៈបុរសម្នាក់ នៅក្នុងគម្ពីរសញ្ញាចាស់ផងដែរ។ គេឌាន ត្រូវបានជ្រើសរើសឲ្យដឹកនាំកងទ័ពអ៊ីស្រាអែល ដែលមានទ័ពខ្លាំងរាប់ពាន់នាក់។ ប៉ុន្តែក្នុងចំណោមពួកគេទាំងអស់ គាត់បានជ្រើសរើសយកតែ 300 នាក់ប៉ុណ្ណោះ។

គេឌាន មានរបៀបដ៏គួរឲ្យចាប់អារម្មណ៍ក្នុងការសម្រាំងជ្រើសរើសទាហានរបស់គាត់។ នៅពេលបុរសទាំងនោះ ផឹកទឹកនៅក្នុងស្ទឹងមួយ មនុស្សភាគច្រើន «ឱនចុះ ហើយផឹកទឹក»។2 គាត់មិនជ្រើសរើសពួកគេទាំងនេះទេ។ មនុស្សមួយចំនួនតូចបានយកដៃក្បង់ទឹកផឹក ពួកគេនៅតែមានការប្រុងប្រយ័ត្នជាប់ជានិច្ច។ ពួកគេគឺជាមនុស្សដែលត្រូវបានជ្រើសរើស។ 3
យើងរស់នៅក្នុងជំនាន់នៃ «សង្គ្រាម ពាក្យចចាមអារាម អំពីសង្គ្រាម និងផែនដីរញ្ជួយនៅកន្លែងផ្សេងៗ»។ 4 ដូចដែលបានព្យាករ «ផែនដីទាំងមូលនឹងនៅក្នុងស្ថានភាពចលាចល» 5 ហើយ «សាតាំងនៅពាសពេញលើផែនដី»។ 6 វាព្យាយាមបំផ្លិចបំផ្លាញអ្វីដែលល្អ និងសុចរិតទាំងអស់។ 7 វាគឺជាលូស៊ីហ្វើរ ដែលត្រូវបានបណ្តេញចេញពីវត្តមានរបស់ព្រះ។ 8 ដើម្បីទប់ទល់នឹងរឿងអស់ទាំងនោះ យើងមានអារម្មណ៍វិជ្ជមានយ៉ាងខ្លាំងអំពីអ្វីដែលមាននៅខាងមុខ។

កងពលដ៏តូចរបស់គេឌានបានទទួលជោគជ័យ ដោយសារ«ពួកគេឈរនឹងនៅត្រង់កន្លែងគេរៀងៗខ្លួន» ដូចដែលកំណត់ត្រាបានថ្លែងទុក។ 9

«គ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នេះ» 10 ចាប់ផ្តើមឡើងដោយការយាងរបស់ព្រះវរបិតា និង

ព្រះរាជបុត្រាមកជួបនឹងក្មេងប្រុសយ៉ូសែប ស្មីធ។11 បន្ទាប់មក ទេវតាមរ៉ូណៃ បានបង្ហាញខ្លួនដល់យ៉ូសែប នៅកន្លែងផ្ទាំងចំណារ ជាព្រះគម្ពីរមរមន ដែលបានកប់លាក់ទុក។ 12 យ៉ូសែប ត្រូវបានប្រទានអំណាចឲ្យបកប្រែផ្ទាំងចំណារនោះ។ 13

អំឡុងពេលការបកប្រែ យ៉ូសែប និងអូលីវើរ ខៅឌើរី បានអានអំពីពិធីបុណ្យជ្រមុជទឹក។ ពួកគាត់បានអធិស្ឋានសុំ ដើម្បីដឹងអំពីអ្វីដែលត្រូវធ្វើ។ 14 នៅទីនេះមានពួកសារទូតទេវតាបានលេចមកឯពួកគាត់ គឺ យ៉ូហាន បាទីស្ទ។ យ៉ូហាន បានប្រគល់ដល់ពួកគាត់នូវបព្វជិតភាពអើរ៉ុន «ដែលកាន់កូនសោទាំងឡាយអំពីការបំរើនៃពួកទេវតា និងអំពីដំណឹងល្អនៃការប្រែចិត្ត និងអំពីបុណ្យជ្រមុជទឹក ដោយការពន្លិចសម្រាប់ការផ្ដាច់បាប»។ 15

សាវកពេត្រុស យ៉ាកុប និងយ៉ូហាន ដែលជាមនុស្សជំនិតរបស់ព្រះអម្ចាស់ នៅក្នុងការបំរើរបស់ទ្រង់ បានលេចមកជាបន្ទាប់ ហើយបានប្រគល់ដល់យ៉ូសែប និង អូលីវើរ នូវបព្វជិតភាពខ្ពស់ជាង 16 ឬ «បព្វជិតភាពដ៏បរិសុទ្ធតាមរបៀបនៃព្រះរាជបុត្រានៃព្រះ»។ 17 តាមព្រះគម្ពីរពន្យល់ បព្វជិតភាពនេះគឺត្រូវបានហៅតាមឈ្មោះរបស់ មិលគីស្សាដែក ជាសង្ឃជាន់ខ្ពស់ដ៏អស្ចារ្យ ដែលអ័ប្រាហាំបានថ្វាយដង្វាយមួយភាគដប់។ 18

បព្វជិតភាពនេះ ក្រោយមកបានក្លាយជាសិទ្ធិអំណាចរបស់ពួកគាត់។ តាមរយៈកូនសោទាំងឡាយនៃបព្វជិតភាព ពួកគាត់អាចមានឯកសិទ្ធិទទួលបានអំណាចទាំងអស់នៃស្ថានសួគ៌។ ពួកគាត់ត្រូវបានបញ្ជាឲ្យនាំដំណឹងល្អទៅកាន់គ្រប់ជាតិសាសន៍ទាំងអស់។ 19

វាមិនដែលងាយស្រួលដើម្បីរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទទេ។ វាមិនងាយស្រួលទេ កាលដែលទ្រង់បាននៅមានព្រះជន្ម ហើយវាមិនងាយស្រួលឡើយ សម្រាប់សាសនាចក្រកាលពីជំនាន់ដើម។ ពួកបរិសុទ្ធសម័យមុន ត្រូវបានស្ថិតនៅក្នុងការរងទុក្ខ និងការប្រឆាំងដែលមិនអាចថ្លែងប្រាប់បាន។ វាមានរយៈពេលជាង 180 ឆ្នាំហើយ ចាប់តាំងពីបព្វជិតភាពត្រូវបានស្ដារឡើងវិញ។ ឥឡូវនេះ យើងមានសមាជិកប្រហែលជា 14 លាននាក់។ ប៉ុន្តែ យើងជាភាគដ៏តូចមួយ បើប្រៀបធៀបនឹងចំនួនមនុស្សរាប់កោដិ៍នាក់នៅលើផែនដី។ ប៉ុន្តែ យើងជាខ្លួនយើង ហើយយើងស្គាល់នូវអ្វីដែលយើងស្គាល់ ហើយយើងនឹងបន្តទៅមុខផ្សព្វផ្សាយដំណឹងល្អ។

ព្រះគម្ពីរមរមន បានបង្ហាញយ៉ាងច្បាស់ថា យើងនឹងពុំដែលមានអំណាចដោយចំនួនឡើយ។ ប៉ុន្តែ យើងមានអំណាចបព្វជិតភាព។ 20

ព្យាការីនីហ្វៃបានសរសេរថា៖ «ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញសាសនាចក្រនៃកូនចៀមនៃព្រះ ហើយសមាជិកនៃសាសនាចក្រមានចំនួនតិចណាស់...ខ្ញុំបានឃើញថា សាសនាចក្រនៃកូនចៀម ដែលជាពួកបរិសុទ្ធរបស់ព្រះ ក៏មាននៅពាសពេញលើផ្ទៃផែនដីដែរ ហើយអំណាចរបស់ពួកគេនៅលើផ្ទៃផែនដីមានចំនួនតូច»។ 21

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានមានប្រសាសន៍ថា៖ «ទោះជានិយាយថា... យើងមានចំនួនតិច បើប្រៀបធៀបនឹង... ពិភពលោកក្តី ប៉ុន្តែយើងអាចប្រៀបធៀបនឹងមេដំបែរ ដែលព្រះអង្គសង្គ្រោះបានមានបន្ទូល ដែលនៅទីបំផុត វានឹងដោរឡើង [ឬលើកឡើង] ពាសពេញពិភពលោក»។ 22

នៅពេលកំណត់មួយ យើងនឹងអាចមានឥទ្ធិពលទៅលើមនុស្សលោកទាំងអស់។ យើងនឹងត្រូវបានគេស្គាល់ថាជានរណា ហើយហេតុអ្វីបានជាយើងជាមនុស្សបែបនេះ។ វាអាចនឹងមើលទៅហាក់ដូចជាអស់សង្ឃឹម មានការលំបាកយ៉ាងខ្លាំង ប៉ុន្តែនោះពុំមែនថាគ្មានសង្ឃឹមទេ យើងនឹងឈ្នះចម្បាំងប្រឆាំងនឹងសាតាំងយ៉ាងប្រាកដ។

ប៉ុន្មានឆ្នាំកន្លងទៅ ខ្ញុំបាននិយាយប្រធានបទមួយអំពី «អ្វីដែលអែលឌើរគ្រប់រូបគួរតែដឹង៖ ជាសៀវភៅណែនាំតូចមួយ អំពីគោលការណ៍ទាំងឡាយនៃការគ្រប់គ្រងបព្វជិតភាព»។ ក្រោយមក នៅពេលវាត្រូវបានបោះពុម្ព ខ្ញុំបានផ្លាស់ចំណងជើងថា ៖«អ្វីដែលអែលឌើរគ្រប់រូបគួរតែដឹង--- ហើយស្ត្រីគ្រប់រូបគួរតែដឹងផងដែរ»។ 23

ខ្ញុំបានបញ្ចូលទាំងស្ត្រីផងដែរ ក៏ព្រោះតែវាសំខាន់សម្រាប់មនុស្សគ្រប់រូប ដើម្បីយល់ពីអ្វីដែលត្រូវបានរំពឹងទុកពីបងប្អូនប្រុស។ លើកលែងតែយើងទទួលបានការយកចិត្តទុកដាក់ពីម្តាយ និងកូនស្រី និងបងប្អូនស្រីទាំងឡាយ ដែលមានឥទ្ធិពលលើ ស្វាមី ឪពុក កូនប្រុស និងបងប្អូនប្រុសរបស់ពួកគេ បើមិនដូច្នោះទេ យើងនឹងមិនអាចរីកចំរើនឡើយ។ បព្វជិតភាពនឹងបាត់បង់អំណាចដ៏មហិមា បើសិនជាបងប្អូនស្រីមិនអើពើរនោះ។

បព្វជិតភាព គឺជាសិទ្ធិអំណាច និងជាអំណាច ដែលព្រះបានប្រទានដល់បុរសនៅលើផែនដី ដើម្បីធ្វើកិច្ចការជំនួសទ្រង់។ 24 នៅពេលសិទ្ធិអំណាចបព្វជិតភាព ត្រូវបានអនុវត្តដោយត្រឹមត្រូវ នោះអ្នកកាន់បព្វជិតភាព ធ្វើនូវអ្វីដែលទ្រង់នឹងធ្វើ បើសិនជាទ្រង់មានវត្តមាន។

យើងបានធ្វើបានយ៉ាងល្អនៅក្នុងការបែងចែក *សិទ្ធិអំណាច* នៃបព្វជិតភាព។ យើងមានសិទ្ធិអំណាចបព្វជិតភាព ដែលបានស្ថាបនាឡើងស្ទើរតែនៅគ្រប់ទីកន្លែង។ យើងមានកូរ៉ុមអែលឌើរ និងសង្ឃជាន់ខ្ពស់ទូទាំងពិភពលោក។ ប៉ុន្តែការបែងចែង *សិទ្ធិអំណាច* នៃបព្វជិតភាព បានរីកចំរើនយ៉ាងរហ័ស ខ្ញុំគិតថារហ័សជាងការបែងចែក *អំណាច* នៃបព្វជិតភាព។  បព្វជិតភាព គឺពុំមានកម្លាំងដែលវាគួរមាន ហើយនឹងពុំមានកម្លាំងទេ រហូតដល់ *អំណាច* នៃបព្វជិតភាព ត្រូវបានរឹងមាំដោយខ្ជាប់ខ្ជួននៅក្នុងក្រុមគ្រួសារ ដូចដែលវាគួរតែមានសិន។

ប្រធាន ហារូល ប៊ី លី បានថ្លែងថា៖ «វាហាក់ដូចជាប្រាប់ខ្ញុំយ៉ាងច្បាស់ថា សាសនាចក្រ *គ្មានជម្រើស* --- ហើយពុំដែលមាន--- ប៉ុន្តែត្រូវធ្វើច្រើនជាង ដើម្បីជួយដល់ *ក្រុមគ្រួសារ* នៅក្នុងការអនុវត្តន៍បេសកកម្មដ៏ទេវភាព *របស់គ្រួសារ* មិនមែនដោយសារតែវាគឺជាអង្គការនៃស្ថានសួគ៌ប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារវាគឺ

ជាការបែងចែក *ដ៏មានប្រយោជន៍បំផុត* ដែលយើងអាចធ្វើចំពោះយុវវ័យរបស់យើង--- ដើម្បីជួយកែលំអរគុណភាពនៃជីវិត នៅក្នុងគេហដ្ឋានរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ។ វាសំខាន់ដូចគ្នានឹងកម្មវិធី និងកិច្ចខិតខំខាងការរៀបចំជាច្រើន របស់យើងផងដែរ ដែលកម្មវិធី និងកិច្ចខិតខំទាំងនេះ *មិនគួរ* មកជំនួសឲ្យគេហដ្ឋានទេ វាគួរតែជួយ *គាំទ្រ* ដល់គេហដ្ឋានវិញ»។ 25

ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានធ្វើសេចក្ដីថ្លែងនេះ អំពីបព្វជិតភាពនៅក្នុងគេហដ្ឋានថា៖ «នៅក្នុងគេហដ្ឋាន សិទ្ធិអំណាចជាអធិបតី គឺត្រូវបានប្រគល់ទៅឲ្យឪពុកជានិច្ច ហើយកិច្ចការក្នុងផ្ទះ និងបញ្ហាគ្រួសារទាំងអស់ គ្មានសិទ្ធិអំណាចណាធំជាងទេ។ ជាឧទាហរណ៍អំពីគោលការណ៍នេះ ឧប្បត្តិហេតុតែមួយនឹងប្រហែលជាគ្រប់គ្រាន់។ ពេលខ្លះ វាបានកើតឡើងថា អែលឌើរ ត្រូវបានហៅឲ្យបំរើដល់សមាជិកគ្រួសារមួយ។ នៅក្នុងចំណោមអែលឌើរទាំងនេះ អាចមានប្រធានស្តេក ពួកសាវក ឬជាសមាជិកនៃគណៈប្រធានទីមួយ នៃសាសនាចក្រ។ នៅក្រោមស្ថានភាពទាំងនេះ វាមិនសមរម្យទេ ដែលឪពុក ត្រូវឈរនៅពីក្រោយ ហើយរំពឹងទុកឱ្យពួកអែលឌើរ ទៅដឹកនាំការបំរើនៃពិធីបរិសុទ្ធដ៏សំខាន់នេះ។ ឪពុកនៅទីនោះ។ វាគឺជាសិទ្ធិរបស់គាត់ ហើយវាគឺជាកាតព្វកិច្ចរបស់គាត់ ដើម្បីធ្វើជាអធិបតី។ គាត់គួរតែជ្រើសរើសម្នាក់ ដែលត្រូវបំរើខាងការចាក់ប្រេង ម្នាក់ដែលត្រូវអធិស្ឋាន ហើយគាត់មិនគួរមានអារម្មណ៍ថា ដោយសារមានវត្តមានសិទ្ធិអំណាចជាអធិបតី នៅក្នុងសាសនាចក្រ ដែលហេតុដូច្នេះហើយ គាត់ត្រូវបានដកហូតនូវសិទ្ធិរបស់គាត់ ដើម្បីដឹកនាំការបំរើនៃពរជ័យនៃដំណឹងល្អ នៅក្នុងគេហដ្ឋានរបស់គាត់នោះទេ។ (បើសិនជាឪពុកអវត្តមាន ម្តាយគួរតែស្នើសុំវត្តមានសិទ្ធិអំណាចជាអធិបតីដើម្បីទទួលខុសត្រូវ) ។ ឪពុកធ្វើជាអធិបតីនៅតុអាហារ ពេលអធិស្ឋាន និងផ្តល់នូវការដឹកនាំទូទៅ ដែលទាក់ទងទៅនឹងជីវិតគ្រួសាររបស់គាត់ដែលមានវត្តមាន»។ 26

អំឡុងសង្គ្រាមវៀតណាម យើងបានធ្វើការប្រជុំពិសេសមួយជាបន្តបន្ទាប់សម្រាប់សមាជិកសាសនាចក្រដែលបានហៅទៅក្នុងការបំរើកងទ័ព។ បន្ទាប់ពីការប្រជុំមួយដូច្នេះនៅទីក្រុង ឈីកាហ្គូ ខ្ញុំបានឈរនៅជិតនឹងប្រធាន ហារូល ប៊ី លី នៅពេលពួកបរិសុទ្ធថ្ងៃចុងក្រោយវ័យក្មេងម្នាក់ បានប្រាប់ដល់ប្រធានលី ថាគាត់សុំច្បាប់ទៅសួរសុខទុក្ខគ្រួសាររបស់គាត់ បន្ទាប់មកទទួលបញ្ជាឲ្យទៅវៀតណាម។ គាត់បានសុំឲ្យប្រធាន លី ផ្តល់ការប្រសិទ្ធពរមួយដល់គាត់។

ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង ពេលប្រធានលីមានប្រសាសន៍ថា «ឪពុករបស់អ្នក គួរតែផ្តល់ការប្រសិទ្ធពរដល់អ្នក»។ យុវជននោះបាននិយាយដោយខកចិត្តថា «ឪពុករបស់ខ្ញុំមិនដឹងរបៀបធ្វើការប្រសិទ្ធពរនេះឡើយ»។

ប្រធានលីបានឆ្លើយថា «កូនប្រុស ចូរទៅផ្ទះចុះ ហើយប្រាប់ឪពុករបស់អ្នកថា អ្នកនឹងចេញទៅធ្វើសង្គ្រាមហើយចង់ទទួលបានការប្រសិទ្ធពររបស់ឪពុក។ បើសិនជាគាត់មិនដឹងពីរបៀបធ្វើ សូមប្រាប់គាត់ថា អ្នកនឹងអង្គុយចុះនៅលើកៅអី។ គាត់អាចឈរនៅពីក្រោយអ្នក ហើយដាក់ដៃលើក្បាលរបស់អ្នក រួចនិយាយនូវអ្វីដែលផុសចេញពីគំនិតរបស់គាត់»។ យុវជនរូបនេះ បានដើរចេញទៅដោយសោកសៅ។

ប្រហែលជាពីរឆ្នាំក្រោយមក ខ្ញុំបានជួបគាត់ម្តងទៀត។ ខ្ញុំមិនចាំថានៅកន្លែងណាទេ។ គាត់បានរំឭកខ្ញុំអំពីបទពិសោធន៍នោះ ហើយនិយាយថា «ខ្ញុំបានធ្វើដូចដែលខ្ញុំបានប្រាប់ឲ្យធ្វើ។ ខ្ញុំបានពន្យល់ដល់ឪពុករបស់ខ្ញុំថា ខ្ញុំនឹងអង្គុយចុះនៅលើកៅអី ហើយគាត់ត្រូវដាក់ដៃពីលើក្បាលខ្ញុំ។ អំណាចបព្វជិតភាពបានមានពោរពេញមកលើយើងទាំងពីរនាក់។ នោះគឺជាកម្លាំង និងជាការការពារ នៅក្នុងចម្បាំងដ៏គ្រោះថ្នាក់ជាច្រើនខែ»។

មានគ្រាមួយទៀត ខ្ញុំបានទៅទីក្រុងដាច់ស្រយាលមួយ។ បន្ទាប់ពីសន្និសីទមួយ យើងត្រូវធ្វើការតែងតាំង និងធ្វើពិធីញែកចេញដល់ពួកអ្នកដឹកនាំ។ នៅពេលយើងបញ្ចប់ ប្រធានស្តេកបានមានប្រសាសន៍ថា «តើពួកយើងអាចតែងតាំងយុវជនម្នាក់ឲ្យធ្វើជាអែលឌើរ ដែលនឹងចាកចេញទៅតំបន់បេសកកម្មបានទេ?» ប្រាកដណាស់ ចម្លើយ គឺថាបាន។

នៅពេលយុវជននោះដើរមក គាត់បានបោយដៃហៅបងប្អូនប្រុសបីនាក់ឲ្យមក ហើយឈរក្នុងរង្វង់សម្រាប់ការតែងតាំងរបស់គាត់។

ខ្ញុំបានកត់សំគាល់នៅជួរក្រោយអំពីភាពស្រដៀងគ្នារបស់យុវជននេះ ហើយបានសួរថា «តើនោះជាឪពុករបស់អ្នកឬ?»

យុវជននោះបាននិយាយថា «បាទ»។ ខ្ញុំបាននិយាយថា «ឪពុករបស់អ្នកនឹងតែងតាំងអ្នក»។ ហើយគាត់បានប្រកែកថា «ប៉ុន្តែ ខ្ញុំបានសុំឲ្យបងប្រុសម្នាក់ទៀត ដើម្បីតែងតាំងឲ្យខ្ញុំរួចហើយ»។

ហើយខ្ញុំបាននិយាយថា «អ្នកកម្លោះ ឪពុករបស់អ្នកនឹងតែងតាំងអ្នក ហើយអ្នកនឹងមានអំណរគុណចំពោះព្រះអម្ចាស់សម្រាប់ថ្ងៃនេះ»។ បន្ទាប់មក ឪពុកបានមក។

អរគុណណាស់ ដែលគាត់ជាអែលឌើរម្នាក់។ គាត់មិនធ្លាប់បានធ្វើ តែមិនយូរទេ គាត់អាចធ្វើបាន! នៅក្នុងកងទ័ព ពួកគេនឹងហៅថា ការដំឡើងឋានៈ។ ពេលខ្លះ រឿងដូច្នេះត្រូវបានធ្វើឡើងនៅក្នុងសាសនាចក្រ។

ឪពុកមិនចេះរបៀបតែងតាំងកូនប្រុសរបស់គាត់ទេ។ ខ្ញុំបានដាក់ដៃឱបគាត់ ហើយបានប្រាប់គាត់ នៅពេលធ្វើពិធីបរិសុទ្ធនោះ។ នៅពេលគាត់បញ្ចប់ យុវជននោះបានក្លាយជាអែលឌើរម្នាក់។ បន្ទាប់មក រឿងដ៏អស្ចារ្យបានកើតឡើង។ ឪពុក និងកូនបានឱបគ្នា ហើយមានការផ្លាស់ប្តូរទាំងស្រុង។ ពិតណាស់ថា ការឱបគ្នានោះមិនធ្លាប់មានពីមុនមកនោះទេ។ តែការឱបគ្នានោះនឹងមានភាពកាន់តែងាយស្រួល បន្ទាប់ពីពេលនេះទៅ។ ចូរគិតថា តើវាមានជោគជ័យច្រើនជាង កាលដែលអ្នកដទៃ បានតែងតាំងគាត់ប៉ុណ្ណាទៅទោះជាសារកក្តី។

ខណៈពេលដែលបព្វជិតភាពកំពុងតែមានវត្តមាននៅពេញពិភពលោក យើងអំពាវនាវដល់ពួកអែលឌើរពួកសង្ឃជាន់ខ្ពស់ និងអ្នកកាន់បព្វជិតភាពគ្រប់រូបឱ្យឈរ ដូចជាកងពលតូចរបស់គេឌាន ប៉ុន្តែជាកងពល 300 នាក់ដ៏មានអំណាច *ឈរនៅត្រង់កន្លែងគេរៀងៗខ្លួន។* ឥឡូវនេះ យើងត្រូវតែដាស់អំណាច

បព្វជិតភាពរបស់ព្រះដ៏មហិទ្ធិឫទ្ធិនៃអែលឌើរ និងសង្ឃជាន់ខ្ពស់គ្រប់រូប កូរ៉ុម និងក្រុមទាំងអស់ ព្រមទាំងឪពុកនៃគ្រប់គេហដ្ឋានទាំងអស់។

ព្រះអម្ចាស់បានមានព្រះបន្ទូលថា «ពួកកំសោយនៅពិភពលោកនឹងចេញមក ហើយទំលាក់ពួកខ្លាំងពូកែចុះ»។ 27

ព្យាការីនីហ្វែក៏បានប្រាប់ផងដែរថា «ព្រះចេស្ដានៃកូនចៀមនៃព្រះ បានយាងចុះមកសណ្ឋិតលើពួកបរិសុទ្ធក្នុងសាសនាចក្រនៃកូនចៀម ហើយលើរាស្ត្រដែលនៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ ដែលបានខ្ចាត់ខ្ចាយពាសពេញលើផ្ទៃផែនដី» ហើយបានប្រាប់ថា «ពួកគេប្រដាប់អាវុធដោយសេចក្ដីសុចរិត និងដោយព្រះចេស្ដានៃព្រះ ដោយសិរីល្អដ៏អស្ចារ្យ»។ 28

យើងត្រូវការមនុស្សគ្រប់រូប។ មនុស្សដែលនឿយហត់ ឬ សឹករិចរិល ឬខ្ជិលច្រអូស ព្រមទាំងអ្នកទាំងឡាយ ដែលចងជាប់ដោយកំហុស ត្រូវតែស្ដារឡើងវិញ តាមរយៈការប្រែចិត្ត និងការអភ័យទោស។ បងប្អូនប្រុសបព្វជិតភាពជាច្រើន កំពុងតែរស់នៅខាងក្រោមបន្ទាត់ឯកសិទ្ធិរបស់ពួកគេ និងការរំពឹងទុករបស់ព្រះអម្ចាស់។

យើងត្រូវតែឆ្ពោះទៅមុខ ដោយមានទំនុកចិត្តនឹងអំណាចដ៏មហិមានៃបព្វជិតភាព។ វាគឺជាធនធាននៃកម្លាំងមួយ ហើយជាការលើកទឹកចិត្តយើង ឱ្យស្គាល់ថាខ្លួនយើងជានរណា ហើយយើងមានអ្វី និងមានអ្វីខ្លះដែលយើងត្រូវតែធ្វើ នៅក្នុងកិច្ចការរបស់ព្រះដ៏រុងរឿង។

ព្រះអម្ចាស់បានមានបន្ទូលថា «យើងជាព្រះអម្ចាស់ជាប់សន្យា កាលណាអ្នករាល់គ្នាប្រព្រឹត្តតាមអ្វី ដែលយើងមានព្រះបន្ទូល ប៉ុន្តែកាលណាអ្នករាល់គ្នាមិនប្រព្រឹត្តតាមអ្វីដែលយើងមានបន្ទូលទេ នោះអ្នករាល់គ្នាពុំមានសេចក្ដីសន្យាឡើយ»។ 29

គេហដ្ឋានទាំងឡាយណាដែលគ្មានអ្នកកាន់បព្វជិតភាពគឺត្រូវមើលថៃ ហើយបំរើដោយកូរ៉ុមបព្វជិតភាព។ តាមរបៀបនេះ នោះគ្រួសារនៅក្នុងសាសនាចក្រនឹងរកឃើញថា ឈប់ស្វែងរកការប្រសិទ្ធពរទៀតហើយ។

អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ មានគ្រួសារមួយបានមកជួបជុំគ្នានៅជិតគ្រែរបស់ស្ត្រីតូចចំណាស់ជនជាតិដាណាម៉ាកម្នាក់។ នៅក្នុងចំណោមពួកគេមានកូនប្រុសវ័យកណ្ដាលមានៈម្នាក់។ អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ គាត់បានរស់នៅក្នុងផ្ទះជាមួយ។

គាត់បានអង្វរដោយស្រក់ទឹកភ្នែកថា «ម៉ាក់ ម៉ាក់ត្រូវតែរស់។ ម៉ាក់ ម៉ាក់មិនអាចស្លាប់បានទេ»។ គាត់និយាយថា «ម៉ាក់ ម៉ាក់មិនអាចទៅបានទេ។ កូនមិនឲ្យម៉ាក់ទៅណាទេ»។

ម្ដាយមាឌតូចម្នាក់នោះ បានមើលមកកូនប្រុសគាត់ ហើយនិយាយរដឹនៗថា «តើអំណាចឯងនៅឯណា?---តើអំណាចកូនមានអំណាចមកពីណា?»

ប៉ុលបាននិយាយថា «[យើង]បានស្អាងឡើងនៅលើជើងជញ្ជាំងនៃពួកសាវកនឹងពួកហោរា ហើយព្រះយេស៊ូវ គ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក ដែលដោយសារទ្រង់ ដំណាក់ទាំងមូលនោះបានផ្គុំភ្ជាប់គ្នា ទាំងចំរើនឡើងជាវិហារបរិសុទ្ធក្នុងព្រះអម្ចាស់ ហើយអ្នករាល់គ្នាក៏បានស្អាងឡើងក្នុងទ្រង់ដែរ សម្រាប់ជាលំនៅនៃព្រះដោយនូវព្រះវិញ្ញាណ»។ 30

កិច្ចការរបស់ព្រះអម្ចាស់នឹងយកឈ្នះដោយគ្មានសំណួរឡើយ។នោះយើងត្រូវតែប្រមូលផ្ដុំកម្លាំងរបស់យើងទាំងអស់ ហើយរួបរួមគ្នា។

សិទ្ធិអំណាចបព្វជិតភាព គឺមាននៅជាមួយយើង។ បន្ទាប់ពីនោះ យើងបានធ្វើសហសម្ព័ន្ធ និងបានរៀបចំឥឡូវនេះ គឺជាការទទួលខុសត្រូវរបស់យើង ដើម្បីធ្វើឲ្យ *អំណាច* នៃបព្វជិតភាពនៅក្នុងសាសនាចក្រ មានភាពសកម្មឡើងវិញ។ *សិទ្ធិអំណាច* នៅក្នុងបព្វជិតភាព កើតមកតាមរបៀបនៃការតែងតាំង *អំណាច* នៅក្នុងបព្វជិតភាពកើតមកតាមរយៈការរស់នៅដោយការគោរពតាមសេចក្តីសញ្ញា ដោយស្មោះត្រង់ និងគោរពប្រតិបត្តិ។ វានឹងរីកចំរើនឡើងដោយសារការអនុវត្តន៍ និងការប្រើប្រាស់បព្វជិតភាពនៅក្នុងសេចក្តីសុចរិត។

ឥឡូវនេះ ឪពុកទាំងឡាយ ខ្ញុំនឹងរំឭកដល់អ្នក អំពីលក្ខណៈពិសិដ្ឋនៃការហៅរបស់អ្នក។ អ្នកមានអំណាចបព្វជិតភាពដោយផ្ទាល់មកពីព្រះ ដើម្បីការពារគេហដ្ឋានរបស់អ្នក។ នឹងមានពេលជាច្រើនដែលអំណាចនោះនឹងឈរធ្វើជាខែលការពាររវាងគ្រួសាររបស់អ្នក និងសេចក្តីអន្តរាយនៃមាសត្រូវ។ អ្នកនឹងទទួលបានការដឹកនាំមកពីព្រះអម្ចាស់ ដោយរបៀបនៃអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។

មាសត្រូវ មិនរំខានដល់ការប្រជុំក្នុងព្រះវិហាររបស់យើងយ៉ាងសកម្មនោះទេ ប្រហែលជាវារំខានតែម្ដងម្កាលប៉ុណ្ណោះ។ ជាទូទៅ យើងមានសេរីភាពដើម្បីជួបប្រជុំគ្នា តាមដែលយើងចង់បាន ដោយគ្មានការរំខានច្រើនទេ។ ប៉ុន្តែវា និងអ្នកទាំងឡាយដែលធ្វើតាមវា ព្យាយាមវាយប្រហារមកលើគេហដ្ឋាន និងគ្រួសារវិញ។

គោលដៅដ៏សំខាន់នៃគ្រប់សកម្មភាពទាំងអស់ក្នុងសាសនាចក្រ គឺថា បុរស និងភរិយារបស់គាត់ និងកូនៗរបស់ពួកគេ អាចនឹងមានការរីករាយនៅក្នុងផ្ទះ បានការពារដោយគោលការណ៍ និងច្បាប់ទាំងឡាយនៃដំណឹងល្អ បានផ្សាភ្ជាប់ដោយសុវត្ថិភាពនៅក្នុងសេចក្តីសញ្ញានៃបព្វជិតភាពដ៏អស់កល្បជានិច្ច។

រាល់ច្បាប់ គោលការណ៍ និងអំណាច រាល់ជំនឿ ពិធីបរិសុទ្ធ និងការតែងតាំង រាល់សេចក្តីសញ្ញាទេសនកថា និងពិធីសាក្រាម៉ង់ រាល់ដំបូន្មាន និងការកែតម្រូវ ការផ្សាភ្ជាប់ ការហៅ ការដោះលែង និងការបំរើ--- ទាំងអស់នេះ មានគោលបំណងសំខាន់របស់វាក្នុងការធ្វើឱ្យបុគ្គល និងគ្រួសារបានល្អឥតខ្ចោះត្បិតព្រះអម្ចាស់បានមានបន្ទូលថា «នេះហើយជាកិច្ចការសិរីល្អរបស់យើង--- គឺដើម្បីនាំឱ្យមានអមតភាព

និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស»។ 31 ហេតុដូច្នេះវានឹងកើតមាន។

កំណត់ចំណាំ

1. Relief Society Magazine ខែ មេសា ឆ្នាំ 1967 ទំព័រ 247។

2. ពួកថៅហ្វាយ 7:6។

3. សូមមើល ពួកថៅហ្វាយ 7:4--8។

4. មរមន 8:30 សូមមើលផងដែរ គ. និង ស. 45:26; យ.ស.--- ម៉ាថាយ 1:23, 28។

5. គ. និង ស. 45:26 សូមមើលផងដែរ គ. និង ស. 88:91។

6. គ. និង ស. 52:14។

7. សូមមើល គ. និង ស. 10:22--23។

8. សូមមើល វិវរណៈ 12:7--9; គ. និង ស. 29:36--37; 76:25--26។

9. ពួកថៅហ្វាយ 7:21។

10. គ. និង ស. 112:30។

11. យ.ស.--- ប្រវត្តិ 1:17។

12. សូមមើល JS---History 1:33--34, 59។

13. សូមមើល ទំព័រចំណងជើងព្រះគម្ពីរមរមន គ. និង ស. 135:3។

14. សូមមើល JS---History 1:68--69។

15. គ. និង ស. 13:1។

16. សូមមើល គ. និង ស. 27:12--13។

17. គ. និង ស. 107:3។

18. សូមមើល គ. និង ស. 107:2--4 សូមមើលផងដែរ ហេព្រើរ 7:1--4; អាលម៉ា 13:15។

19. សូមមើល គ. និង ស. 42:58។

20. សូមមើល នីហ្វៃទី 1 14:14។

21. នីហ្វៃទី 1 14:12។

22. Conference Report ខែ តុលា ឆ្នាំ 1968 ទំព័រ 123។

23. Ensign, ខែ កុម្ភៈ ឆ្នាំ 1993 ទំព័រ 4--13។

24. សូមមើល Gospel Doctrine: Selections from the Sermons and Writings of Joseph F. Smith ប្រមូលផ្ដុំដោយ John A. Widtsoe ទំព័រ 136 ក.យ.ស. លោកុប្បត្តិ 14:28--31។

25. The Teachings of Harold B. Lee បានបោះពុម្ពដោយ Clyde J. Williams ទំព័រ 263 បន្ថែមអក្សរទ្រេត។

26. Gospel Doctrine: Selections from the Sermons and Writings of Joseph F. Smith រៀបរៀងដោយ John A. Widtsoe ទំព័រ 287។

27. គ. និង ស. 1:19។
28. នីហ្វៃទី 1 14:14។
29. គ. និង ស. 82:10។
30. អេភេសូ 2:20--22។
31. ម៉ូសេ 1:39។